ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

*ថ្ងៃ ចន្ទ ១៥កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន

នៅថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ នៅខេត្តសៀមរាប **លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា** និង **ឯកឧត្តម Eli M. Remolona, Jr. ទេសាភិបាល ធនាគារកណ្តាលហ្វីលីពីន** បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំទ្វេភាគី និងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាលទាំងពីរ។

កិច្ចប្រជុំទ្វេភាគីកម្រិតខ្ពស់រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន បានផ្លាស់ប្តូរទស្សនៈលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដំណើរវិវឌ្ឍន៍នៃប្រព័ន្ធទូទាត់ បញ្ញាសិប្បនិម្មិត និងសន្តិសុខសាយប័រ និងហិរញ្ញវត្ថុប្រកបដោយចីរភាព ក៏ដូចជា ពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការបន្តកិច្ចសហប្រតិបត្តិការលើការងារ និងគំនិតផ្តួចផ្តើមនានារបស់ធនាគារកណ្តាលទាំងពីរ។

អនុស្សរណៈយោគយល់នេះសបញ្ជាក់ឱ្យឃើញពីឆន្ទៈ និងស្មារតីប្តេជ្ញារបស់ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន ក្នុងការបង្កើតក្របខ័ណ្ឌជាក់លាក់មួយ សម្រាប់ដំណើរការសម្របសម្រួលក៏ដូចជាពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងធនាគារកណ្តាលទាំងពីរ ដែលកន្លងមកតែងតែមានកិច្ចសហប្រតិបត្តិការល្អជាមួយគ្នាក្នុងក្របខ័ណ្ឌទាំងទ្វេភាគីនិងតំបន់។

តាមរយៈលទ្ធផលនៃកិច្ចប្រជុំទ្វេភាគី និងអនុស្សរណៈយោគយល់នេះ ធនាគារកណ្តាលទាំងពីរនឹងពង្រឹងកិច្ចសហប្រតិបត្តិការថែមទៀត ជាពិសេសក្នុងផ្នែកពាក់ព័ន្ធនឹងប្រព័ន្ធប្រតិបត្តិការធនាគារកណ្តាល ការតភ្ជាប់និងនវានុវត្តន៍ប្រព័ន្ធទូទាត់ នវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល ការត្រួតពិនិត្យប្រព័ន្ធធនាគារ ការអភិវឌ្ឍធនធានមនុស្ស និងផ្នែកផ្សេងៗជាច្រើនទៀតសម្រាប់ផលប្រយោជន៍ទៅវិញទៅមក៕

**ទំនាក់ទំនង៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia ,
www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA